# វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រង គំរោងកម្មវិធី និងការចុះបញ្ជីស្នាម

# (TRAINING COURSE ON PROJECT MANAGEMENT AND BOOK KEEPING)

សំរាប់ គ.អ.ភ. និង អនុគណកម្មការ

**(For VDC and PSC)**




**អង្គការ ស៊ីដសេ**

**កម្មវិធីគាំទ្រការបណ្តុះបណ្តាលអភិវឌ្ឍន៍សហគមន៍**

**(CIDSE Field Training Support Unit)**

# និយមន័យនៃសហគមន៍

**(DEFINITION OF COMMUNITY)**

ដើម្បីអនុវត្តការងារអោយមានប្រសិទ្ធិភាពខ្ពស់ និងប្រកបដោយគុណភាពល្អ ក្នុងនាមជាភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ គួរគប្បីស្វែងយល់ពីជីវភាពរស់នៅរបស់សហគមន៍ដែលជាក្រុមគោលដៅរបស់អ្នក នោះគឺជំនឿទំនៀមទំលាប់ប្រពៃណី រឿងរ៉ាវផ្សេងៗ និងសមត្ថភាពពិសេសរបស់សហគមន៍ ។ លើសពីនេះទៅទៀត គួរស្វែងយល់ពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍ ព្រោះវាជាមធ្យោបាយដ៏ល្អ សំរាប់ជួយអ្នកអោយដឹងពីរបៀបប្រាស្រ័យទាក់ទងក្នុងជីវភាពរស់នៅ និងការគ្រប់គ្រងនៅក្នុងសហគមន៍ ។

## 🕮 តើសហគមន៍ជាអ្វី ?

បើតាមវចនានុក្រមខ្មែររបស់សម្តេចសង្ឃជួនណាត់ទំព័រ ១៣១៩ មានន័យពីរយ៉ាងគឺសហគមន៍ ( សហ = ជាមួយគ្នា. រួមគ្នា + គមន = ដំណើរទៅ ⇨ ការទៅជាមួយ ឬដំណើរជាមួយ

⇨ ប្រជុំភូមិ ឬតំបន់អ្នកស្រុកប្រកបមុខរបរចូលគ្នា. . . បង្កើតអោយមានសហគមន៍ ។

បើតាមភាសាអង់គ្លេស **Community < Commune =** ទាក់ទងដោយអារម្មណ៍.ឃុំ **+ Unity =** សាមគ្គីភាព. ឯកភាព ។

⇨ ក្រុមមនុស្សដែលរស់នៅកន្លែងណាមួយក្នុងស្រុក ឬប្រទេសដោយគិតពីផលប្រយោជន៍រួម : ធ្វើការដើម្បី សហគមន៍មួយល្អ រីកចំរើន ជឿនលឿន ។

☞ ១- មានមតិខ្លះបានគិតថា សហគមន៍ គឺជាក្រុមមនុស្សដែលរស់នៅមានទីកន្លែងពិតប្រាកដ ( ភូមិ) មានផលប្រយោជន៍រួម និងស្ថានភាពរស់នៅប្រហាក់ប្រហែលគ្នា ។

តាមទស្សនៈមតិនេះ បានគូសបញ្ជាក់ទៅលើអ្វីដែលមនុស្សមានលក្ខណៈជារួម ។ ការប្រាស្រ័យទាក់ទងរវាងសមាជិកនៅក្នុងសហគមន៍ អាចទទួលស្គាល់ជាមូលដ្ឋាន គឺស្រុះស្រួលគ្នាបានល្អ ។

☞ ២- មតិផ្សេងៗទៀតបានពោលថា ក្នុងទិដ្ឋភាពរស់នៅជាក់ស្តែងរបស់មនុស្សម្នាក់ៗនៅក្នុងភូមិជងរបងជាមួយគ្នាមិនបានទទួលផលកំរៃទាំងអស់ដូចៗគ្នា ឬមានការស្រុះស្រួលជាមួយនឹងគ្នាជានិច្ចនោះទេ ។ អ្នកខ្លះខ្ចី ឬអោយគេខ្ចីលុយ បុលស្រូវដោយអត្រាការប្រាក់ខ្ពស់ ក្មេងខ្លះចូលរៀន ខ្លះនៅផ្ទះជួយកិច្ចការឪពុកម្តាយ ខ្លះនិយាយស្តីខ្លាំងៗ ខ្លះមិនហ៊ានហើបមាត់ ខ្លះនិយាយបង្គាប់បញ្ជាគេឯងអោយគេកោតខ្លាច ខ្លះអនុវត្តន៍តាម ខ្លះមានអំណាច ឥទ្ធិពល និងមានមោទនភាពចំពោះខ្លួនឯង ចំណែកអ្នកខ្លះទៀតមានអំណាចតិចតួច ឬគ្មានសោះ ជាពិសេសស្ត្រីត្រូវបានគេរើសអើង និងប្រទះនូវអំពើហិង្សាក្នុងគ្រួសារ ។

នៅក្នុងសហគមន៍ ទោះជាអ្នកក្រីក្រ និងមានអំណាចតិចតួចក៏ដោយ ជួនកាលគេក៏អាចចេះបែងចែកការរស់នៅរបស់ខ្លួនគេបានដែរ ។ អ្នកខ្លះការពារផលប្រយោជន៍ពួកអ្នកមានអំណាច ឃុបឃិតជាមួយពួកឈ្មួញទុច្ចរិត ដើម្បីលាភសក្ការៈរបស់ខ្លួន ។

អ្នកដទៃទៀតរស់នៅ ដោយយកការបោកប្រាស់ កេងប្រវ័ញ្ច លេងល្បែង លួចប្លន់ ស៊ីផឹកជាអំពើត្រីមុខ។ ខ្លះរស់នៅដោយស្ងៀមស្ងាត់បណ្តោយខ្លួនទៅតាមយថាកម្ម មានការទាស់ទែងគ្នា និងខ្លះចេះឈឺឆ្អាលជួយយក អាសារគ្នាទៅវិញទៅមក ។

ដូច្នេះយើងសង្កេតឃើញថា ចំពោះស្ថានភាពជាក់ស្តែងនៅក្នុងសហគមន៍ភាគច្រើន មនុស្សម្នាក់ៗមានទឹកចិត្តមិនដូចគ្នាទេ តាំងពីកំរិតមូលដ្ឋានរហូតដល់គ្រប់ខ័ណ្ឌជាតិ និងពិភពលោកទាំងមូល ។

វាអាចនឹងមានការដូចគ្នា ឬផ្ទុយគ្នាទៅតាមរបៀបអ្នកខ្លាំង និងអ្នកខ្សោយ អំពើយុត្តិធម៌ ឬអយុត្តិធម៌ ឧត្តរដ្ឋ ឬអនាធិបតេយ្យ លទ្ធិប្រជាធិបតេយ្យ ឬផ្តាច់ការ លោភអំណាច ឬមិនញៀននឹងអំណាច មានបញ្ហាដូចគ្នា និងធ្វើអភិវឌ្ឍន៍ដើម្បីប្រយុទ្ធនឹងភាពក្រីក្រ ។

ក្នុងគោលគំនិតខាងលើនេះ ប្រជាជនយើងនឹងអាចធ្វើការជាមួយគ្នាបានល្អ ប្រកបដោយសុខដុមរមនា ព្រោះការរស់នៅជាមួយគ្នានោះ គឺជាប្រពៃណីបរមបុរាណមួយរបស់ពួកគេ ។

ធាតុនៃការចុះសំរុងនឹងគ្នា និងការបែងចែកផលប្រយោជន៍ មាននៅគ្រប់សហគមន៍ ប៉ុន្តែមិនចុះសំរុងនឹងគ្នា ក៏កើតមានផងដែរ ។ ហេតុការណ៍ទាំងឡាយនេះមានឥទ្ធិពលយ៉ាងធំធេងទៅលើការរស់នៅរបស់ប្រជាជន ក៏ដូចជាភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ដែរ ត្រូវតែប្រឈមមុខចំពោះព្រឹត្តិការណ៍បែបនេះ ព្រោះវាជាគោលដៅនៃកម្មវិធីអភិវឌ្ឍន៍ ដែលជួយសហគមន៍អោយជឿនលឿនប្រកបដោយនិរន្តភាព តាមរបៀបជួយខ្លួនឯង អ្នកក្នុងត្រូវតែធ្វើ តែអ្នកក្រៅអាចជួយ ។

☞ - ដូចសំដីមហាត្មះគន្ធី បានពោលថា បើអ្វីៗសព្វសារពើដែលគេបានធ្វើ សំរាប់ខ្ញុំ ប៉ុន្តែមិនមែនជាមួយខ្ញុំ នោះ គឺអំពើនោះវាប្រឆាំងនឹងខ្ញុំ ។

- ជួយខ្លួនឯងជាមុនសិន ទើបព្រះជួយ

- ព្រះពុទ្ធបានទូន្មានពុទ្ធបរិស័ទថា អត្តាហិ អត្តនោនាថោ = ខ្លួនទីពឹងខ្លួន ។

# ធាតុនៃគំរោងកម្មវិធី
## (ELEMENT OF PROJECT)

## 🕮 តើគំរោងកម្មវិធីជាអ្វី ?

បើតាមវចនានុក្រមខ្មែររបស់សម្តេចសង្ឃ ជួន ណាត ទំព័រ ២៦ និង ១៣១ គំរោងកម្មវិធី < គំរោង = ប្រុងទុក, រៀបចំទុកជាមុន + កម្មវិធី = របៀប ឬបែបផែននៃកិច្ចការដែលត្រូវធ្វើ ។

⇨ ការរៀបចំទុកជាមុននូវបែបផែនកិច្ចការដែលត្រូវធ្វើ ។

☞ គំរោងកម្មវិធី គឺជាបណ្តុំនៃគោលបំណង ដើមទុន សកម្មភាព និងលទ្ធផល រៀបចំឡើងដើម្បីដោះស្រាយនូវបញ្ហាសេដ្ឋកិច្ចសង្គមណាមួយដែលបានកំណត់ទុក ។

## 🕮 ធាតុនៃគំរោងកម្មវិធីជាអ្វី ?

គឺជាបណ្តាផ្នែកទាំងឡាយដែលប្រើប្រាស់ សំរាប់ទ្រទ្រង់គំរោងកម្មវិធីអោយមានដំណើរការជាប្រក្រតី :

១_ **គោលបំណង** (Objectives) គឺជាសេចក្តីថ្លែងអំពីអ្វីដែលគំរោងកម្មវិធីមានបំណងចង់ធ្វើ ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចសង្គមណាមួយច្បាស់លាស់ ។ វាបង្ហាញពីលទ្ធផល និងឥទ្ធិពលនៃគំរោងកម្មវិធីទៅលើអ្នកទទួលផល និងសហគមន៍ ។

២_ **លទ្ធផល** (Outputs) គឺជាការសំរេចបាននូវលទ្ធផលជាសំភារៈនៃគំរោងកម្មវិធីមួយដែលកើតឡើងពីសកម្មភាពផ្សេងៗ ។ លទ្ធផលនេះជាការចាំបាច់ណាស់ សំរាប់អោយគេទទួលបាននូវគោលបំណងនៃគំរោងកម្មវិធី ។

៣_ **សកម្មភាព** (Activities) គឺជាស៊េរីនៃកិច្ចការដែលទាក់ទងគ្នាទៅវិញទៅមក ដើម្បីចូលរួមបង្កើតលទ្ធផល ។

៤_ **ដើមទុន** (Inputs) គឺជាធនធានសំខាន់ៗសំរាប់យកទៅអនុវត្តសកម្មភាពផ្សេងៗសំដៅបង្កើតនូវលទ្ធផលផ្សេងៗដែលចាំបាច់ សំរាប់ឈានទៅសំរេចគោលបំណងនៃគំរោងកម្មវិធី ។

ដូច្នេះធាតុនៃគំរោងកម្មវិធី គឺជាមធ្យោបាយមួយដ៏ល្អ ក្នុងការដោះស្រាយបញ្ហាផ្សេងៗ ដែលកើតឡើងនៅក្នុងសហគមន៍ ។ គេត្រូវការដើមទុន ដើម្បីរៀបចំសកម្មភាពដែលចាំបាច់សំរាប់បង្កើតលទ្ធផល ហើយលទ្ធផលជាអ្នកធ្វើអោយឈានសំរេចគោលបំណងដែលគ្រោងទុក ។

គោលការណ៍ណែនាំយ៉ាងល្អបំផុត ដើម្បីធានាអោយគំរោងកម្មវិធីទទួលបានជោគជ័យគឺ អ្នកគ្រប់គ្រងត្រូវសង្កត់ធ្ងន់ទៅលើសំណុំឯកសារនៃគំរោងកម្មវិធី ជាពិសេសទៅលើធាតុរបស់វានោះគឺ :

- គោលបំណង
- លទ្ធផល
- សកម្មភាព
- ដើមទុន

ចំពោះចំណុចទាំង ៤ ខាងលើ លទ្ធផលគឺជាគោលការណ៍ណែនាំយ៉ាងសំខាន់ ចំពោះការគ្រប់គ្រងគំរោងកម្មវិធី ។ នៅក្នុងខួបនៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ ត្រូវតែពិនិត្យ

# ខួបនៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍
## (COMMUNITY DEVELOPMENT PROJECT CYCLE)

## 🕮 ខួបនៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ជាអ្វី ?

ការគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ អាចទទួលបានជោគជ័យ អាស្រ័យលើអ្នកគ្រប់គ្រងគំរោងកម្មវិធីមានទឹកចិត្តប្តេជ្ញាខ្ពស់ គ្រប់គ្រងគំរោងកម្មវិធីប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ក្នុងវិជ្ជាជីវៈ ។

ការគ្រប់គ្រងគំរោងកម្មវិធីប្រកបដោយប្រសិទ្ធិភាពខ្ពស់ បានបង្ហាញដល់អ្នកគ្រប់គ្រងចាំបាច់ត្រូវយល់ដឹងពីខួបនៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍អោយបានច្បាស់លាស់ ។

ខួបនៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ គឺជាដំណើរប្រព្រឹត្តទៅនៃការវិលជុំរបស់គំរោងកម្មវិធី ។

☞ **១_ ការស្វែងយល់ពីសហគមន៍** : គឺជាដំណើរការនៃការកំណត់បញ្ហា ការជ្រើសរើសវិធីសាស្ត្រ និងរៀបចំផែនការចុះទៅសហគមន៍ ការប្រមូលនិងចងក្រងទិន្នន័យ ការវិភាគ និងបង្ហាញលទ្ធផលដែលរកឃើញ ការសន្និដ្ឋាន និងផ្តល់មតិណែនាំ ។

ការស្វែងយល់ពីសហគមន៍ គឺមានគោលបំណងដើម្បីកំណត់បញ្ហាក្នុងការឆ្លើយតបទៅតាមតំរូវការជាក់ស្តែងរបស់សហគមន៍ និងកំណត់ទុកជាទិន្នន័យ គោលសំរាប់ធ្វើការវាយតំលៃរបស់គំរោងកម្មវិធី ។ ការស្វែងយល់គ្មានការអនុវត្តន៍ គឺគ្មានរសជាតិ ធ្វើអោយសហគមន៍គ្មានការរីកចំរើន លឿនលឿន ដូចរុក្ខជាតិរង់ចាំទឹកសឡើម ដើម្បីដុះដាល ផ្ទុយទៅវិញការអនុវត្តន៍គ្មានការស្វែងយល់ ប្រៀបបានដូចជាការអនុវត្តន៍ធ្វើដោយគ្មានហេតុផល ធ្វើទាំងងងឹតងងុល គ្មានគោលដៅច្បាស់លាស់ មិនអាចឆ្លើយតបអោយចំទៅតាមតំរូវការជាក់ស្តែងរបស់សហគមន៍ រីកចំរើនមិនបានត្រឹមត្រូវ គ្មាននិរន្តភាពដូចផ្ការីក ហើយរុះរោយយ៉ាងដូច្នេះដែរ ។

☞ **២_ ការធ្វើផែនការ** : គឺជាដំណើរការនៃការកំណត់បញ្ហា កំណត់គោលដៅ និងគោលបំណងកំណត់ធនធានរៀបចំផែនការអនុវត្តន៍ (យុទ្ធសាស្ត្រ វិធីសាស្ត្រ សន្ទស្សន៍ត្រួតពិនិត្យ និងវាយតំលៃ) ។ រៀបចំគំរោងថវិការ និងការសរសេរសំណើពាក្យគន្លឹះទៅក្នុងការធ្វើផែនការ គឺជាការផ្លាស់ប្តូរឆ្ពោះទៅរកគោលដៅដែលចង់បាន សំរាប់កែប្រែស្ថានភាព ដើម្បីអោយបញ្ហាទាំងនោះដែលដោះស្រាយបាន ។ តើយើងចង់សំរេចបានអ្វី ? ការធ្វើផែនការបានល្អិតល្អន់ អាចជួយកាត់បន្ថយបាននូវភាពអតិបរិមាពីការប្រថុយប្រថាន និងដើម្បីធានាបាននូវលទ្ធផលជាទីគាប់ប្រសើរ ។

☞ **៣_ ការអនុវត្តន៏ :** គឺជាការដំណើរការនៃការសិក្សាពីផែនការ និងការប្តេជ្ញាចិត្តចំពោះការងារ ការប្រមូលធនធានការអនុវត្តន៏ និងសំរបសំរួលទៅការងារតាមជំហាននិមួយៗ ការត្រួតពិនិត្យ (ធនធាន និងលទ្ធផលដែលរំពឹងទុកសំរាប់ចំណាយថវិការ) និងការរំលឹកឡើងវិញ ការដោះស្រាយបញ្ហាជាគន្លឹះសំខាន់ក្នុងការអនុវត្តន៏ការងារ គឺ ការទទួលលទ្ធផលដែលសំរេចបាន និងការធ្វើរបាយការណ៏ ។

ភាពទទួលខុសត្រូវចំពោះការងារ គឺជាការធ្វើសេចក្តីសំរេចចិត្តចំពោះការងាររួមដែលខ្លួនបានធ្វើ ។ នៅពេលដែលអនុវត្តន៏ការងារ អ្នកអនុវត្តន៏ទាំងឡាយតែងតែមានសេចក្តីរីករាយអំណរទៅនឹងលទ្ធផលដែលខ្លួនបានគ្រោងទុក ឬរំពឹងទុក ។ នៅពេលដែលការងារមិនទទួលបានដូចបំណង គេក៏មិនបន្ទោសគ្នា គេនឹងខិតខំស្វែងរកពីបញ្ហាកំហុសឆ្គងទាំងឡាយដែលកើតឡើង ហើយខិតខំដោះស្រាយបញ្ហាទាំងនោះទៅតាមសន្តិវិធី បែងចែកបន្ទុកនៃភាពទទួលខុសត្រូវសារជាថ្មី ហើយខិតខំរៀនមេរៀនពីកំហុសដែលមាន ។

☞ **៤_ ការវាយតំលៃ :** គឺជាដំណើរការនៃការបង្កើតគោលបំណង និងក្រុមវាយតំលៃ ការជ្រើសរើសសន្ទស្សន៏អភិវឌ្ឍន៏ បង្កើតសំភារៈត្រួតពិនិត្យ និងវាយតំលៃ ការចាត់ចែងភាពទទួលខុសត្រូវ ការប្រមូលទិន្នន័យវិភាគ និងផ្តល់ចំលើយការធ្វើរបាយការណ៏ និងផ្សព្វផ្សាយ និងប្រើអនុសាសន៏ ដើម្បីកែលំអរគំរោងកម្មវិធី ។

ការវាយតំលៃ ជាធម្មតាផ្អែកទៅលើការវិនិច្ឆ័យពីអ្នកខាងក្រៅ ។ ការវិនិច្ឆ័យត្រូវយោងទៅតាមលក្ខណៈវិនិច្ឆ័យ និងបទដ្ឋានដែលបានកំណត់ ការមិនបានគោរពដល់គោលការណ៏នៃការវាយតំលៃរួមគ្នា ជាមួយប្រជាជនដើម្បីផលប្រយោជន៏សហគមន៏ និងអង្គការនោះ វាជាសញ្ញានៃការទទួលបរាជ័យ ក្រោមទំរង់នៃការទំពឹងទុក និងការជ្រៀតជ្រែកពីសំណាក់អ្នកក្រៅ ។

# ខួបនៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍



# ខួបនៃការគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍
# (COMMUNITY DEVELOPMENT PROJECT MANAGEMENT CYCLE)

## 🕮 ខួបនៃការគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ជាអ្វី ?

ការគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ អាចទទួលបានជោគជ័យ អាស្រ័យលើអ្នកគ្រប់គ្រងគំរោងកម្មវិធីមានទឹកចិត្តប្តេជ្ញាខ្ពស់ គ្រប់គ្រងគំរោងកម្មវិធីប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ក្នុងវិជ្ជាជីវៈ ។

ការគ្រប់គ្រងគំរោងកម្មវិធីប្រកបដោយប្រសិទ្ធិភាពខ្ពស់ បានបង្ហាញដល់អ្នកគ្រប់គ្រងចាំបាច់ត្រូវយល់ដឹងពីខួបនៃការគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍អោយបានច្បាស់លាស់នោះគឺ :

☞ **១- ការស្រាវជ្រាវ** : **(Research)** គឺជាដំណើរការនៃការកំណត់បញ្ហា ការជ្រើសរើសវិធីសាស្ត្រ និងរៀបចំផែនការស្រាវជ្រាវ ការប្រមូលនិងចងក្រងទិន្នន័យ ការវិភាគ បង្ហាញលទ្ធផលដែលរកឃើញ ការសន្និដ្ឋាន និងធ្វើមតិណែនាំ ។

ការស្រាវជ្រាវ គឺមានគោលបំណងដើម្បីកំណត់បញ្ហាក្នុងការឆ្លើយតបទៅតាមតំរូវការជាក់ស្តែងរបស់សហគមន៍ និងកំណត់ទុកជាទិន្នន័យ គោលសំរាប់ធ្វើការវាយតំលៃរបស់គំរោងកម្មវិធី ។ ការស្វែងយល់គ្មានការអនុវត្តន៍ ពោល គឺគ្មានរសជាតិ ធ្វើអោយសហគមន៍គ្មានការរីកចំរើន ជឿនលឿន ដូចរុក្ខជាតិរង់ចាំទឹកសន្សើម ដើម្បីដុះដាល ផ្ទុយទៅវិញការអនុវត្តន៍គ្មានការស្វែងយល់ ប្រៀបបានដូចជាការអនុវត្តន៍ធ្វើដោយគ្មានហេតុផល ធ្វើទាំងងងឹតងងុល គ្មានគោលដៅច្បាស់លាស់ មិនអាចឆ្លើយតបអោយចំទៅតាមតំរូវការជាក់ស្តែងរបស់សហគមន៍ រីកចំរើនមិនបានត្រឹមត្រូវ គ្មាននិរន្តភាពដូចផ្ការីក ហើយរុះរោយយ៉ាងដូច្នេះដែរ ។

☞ **២- ការធ្វើផែនការ** : **(Planning)** គឺជាដំណើរការនៃការកំណត់បញ្ហា កំណត់គោលដៅ និងគោលបំណងប្រមូលពត៌មាន និងការវិភាគ កំណត់ធនធាន រៀបចំយុទ្ធសាស្ត្រ និងវិធីសាស្ត្រការងារ រៀបចំផែនការអនុវត្តន៍ រៀបចំសន្ទស្សន៍ត្រួតពិនិត្យ និងវាយតំលៃ ។

☞ **៣- ការអនុវត្តន៍** : **(Organizing)** គឺជាការដំណើរការនៃការរៀបចំអង្គការលេខ ការកំណត់ទីកន្លែងអនុវត្តន៍ និងធនធានប្រើប្រាស់ ចំនួនអ្នកចូលរួម និងអ្នកទទួលខុសត្រូវទៅតាមមុខការនិមួយៗ ។

☞ **៤- ការរៀបចំបុគ្គលិក** : **(Staffing)** គឺជាដំណើរការនៃការជ្រើសរើសបុគ្គលិកចូលធ្វើការ ការបណ្តុះបណ្តាលក្នុងការងារ ការរៀបចំបញ្ជីឈ្មោះបុគ្គលិក ការរៀបចំបញ្ជីមុខតំណែងការងារ ការតំឡើងឋានៈ ការដោះស្រាយជំលោះ ។

☞ ៤- **ការដឹកនាំ** : (Leading) គឺជាដំណើរការនៃការកំណត់គោលដៅរបស់អង្គការ/គោលបំណងគំរោងកម្មវិធី ការធ្វើផែនការ និងស្វែងរកធនធាន ការអនុវត្តន៍និងវាយតំលៃ ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារ ដឹកនាំការប្រជុំ សំរបសំរួល ជំរុញលើកទឹកចិត្តនិងគាំទ្រសមាជិក ។

☞ ៦- **ការត្រួតពិនិត្យ និងវាយតំលៃ** : (Monitoring and Evaluation) គឺជាដំណើរការនៃការកំណត់ផែនការវាយតំលៃ ការប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រក្នុងការវាយតំលៃ ការប្រមូលពត៌មាន ការវិភាគនិងអធិប្បាយ ផ្សព្វផ្សាយ និងសរសេររបាយការណ៍ ការផ្តល់មតិណែនាំ ផលប្រយោជន៍នៃការប្រើប្រាស់ ។

☞ ៧- **ការគ្រប់គ្រងថវិការ** : (Budgetting) គឺជាដំណើរការនៃការធ្វើគំរោងផែនការ ស្រង់ចូលបញ្ជីចំណូល និងចំណាយ បូកសរុបថវិការ ការវាយតំលៃលើរបាយការណ៍ គណនេយ្យ ។

ការគ្រប់គ្រងថវិការ មានគោលបំណងដើម្បីប្រើប្រាស់ថវិការអោយចំទិសដៅសន្សំសំចៃ និងអស់លទ្ធភាព ព្រោះថវិការជាធនធានមួយពិបាករក ហើយតំរូវការវាជានិច្ចជាកាលមានកំរិតខ្ពស់ ។

ការគ្រប់គ្រងគំរោងកម្មវិធីនេះ គឺវាទាក់ទិនទៅនឹងប្រព័ន្ធគោលដៅ គោលបំណង ដើមទុន សកម្មភាព លទ្ធភាព គឺឆ្លើយតបទៅនឹងគោលបំណងនៃគំរោងកម្មវិធី ដែលស្ថិតនៅក្រោមការប្រឹងប្រែងរបស់សកម្មភាព អាស្រ័យទៅនឹងការប្រើប្រាស់ដើមទុន ។

យើងមានសមត្ថភាព និងមធ្យោបាយអាចគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍បាន តែកំររកបាននូវអ្នកគ្រប់គ្រងមួយដែលប្រកបដោយសុឆន្ទះ ។

ដូច្នេះអ្នកគ្រប់គ្រងដែលល្អ គួរប្រតិបត្តិតាមគំនិតប្រកបដោយសុឆន្ទះនោះគឺ :

| | |
|---|---|
| ១- ស្រឡាញ់ និងចូលចិត្តការងារ | ⇨ បំពេញការងារអោយបានជោគជ័យ |
| ២- ភាពក្លាហាន | ⇨ ជំនះរាល់ឧបសគ្គ និងផ្លាស់ប្តូរមុខមាត់សហគមន៍ |
| ៣- ភាពដឹកនាំ | ⇨ សំរបសំរួលការងារ ជំរុញលើកទឹកចិត្តធ្វើអោយគំរោងកម្មវិធីមានឥទ្ធិពលវិជ្ជមាន |
| ៤- ទឹកចិត្តប្តេជ្ញាខ្ពស់ | ⇨ ភាពទទួលខុសត្រូវក្នុងការងារកំចាត់បង់នូវអំពើពុករលួយ |
| ៥- ជំនាញ | ⇨ សំរាំងគំរោងផែនការអោយមានប្រសិទ្ធិភាពខ្ពស់ |
| ៦- សមត្ថភាព | ⇨ អនុវត្តន៍ការងារអោយចំទិសដៅ ចេះច្នៃប្រឌិតបទបែនតាមកាលៈទេសៈ |
| ៧- បំណងល្អ | ⇨ សំរេចការងារអោយបានលឿន, ច្រើន និងគុណភាពល្អយូរអង្វែង |

# ខួបនៃការគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍



# រូបមន្តដែលទទួលជោគជ័យសំរាប់អ្នកគ្រប់គ្រងការងារអភិវឌ្ឍន៍
# (THE SUCCESS FORMULA FOR DEVELOPMENT MANAGERS)

## ១. <u>បុព្វហេតុនៃការគ្រប់គ្រងមិនល្អ</u> : (Cause for Mismanagement)

គំរោងកម្មវិធីអភិវឌ្ឍន៍ រមែងតែបរាជ័យដោយសារអ្នកគ្រប់គ្រងយល់មិនបានច្បាស់លាស់អំពី :

- គំរោងកម្មវិធី
- ការគ្រប់គ្រង
- តួនាទី និងមុខងាររបស់គាត់ដែលជាអ្នកគ្រប់គ្រង

អ្នកគ្រប់គ្រងគំរោងកម្មវិធីអភិវឌ្ឍន៍ច្រើនគិតថា គំរោងកម្មវិធី គឺជាបណ្តាសកម្មភាពដែលត្រូវអនុវត្ត ដើម្បីសំរេចបាននូវគោលបំណង ។ ការគ្រប់គ្រងគឺជាការធ្វើផែនការ និងការអនុវត្តគំរោងកម្មវិធី ។ តួនាទីចំបងរបស់គាត់ គឺអ្នកធ្វើផែនការ និងអ្នកអនុវត្តន៍ផែនការ ។

ដោយសារភាពមិនសមស្របនេះហើយ ទើបគំរោងកម្មវិធីទទួលបរាជ័យដោយសារតែអ្នកគ្រប់គ្រង :

- ធ្វើការច្រើនទៅលើសកម្មភាពដែលមិនចាំបាច់ ដែលមិនចូលរួមធ្វើអោយទទួលបាននូវលទ្ធផលនៃគំរោងកម្មវិធី ដែលបានបញ្ជាក់នៅក្នុងឯកសារគំរោងកម្មវិធី ។
- មិនដឹងពីការរីកចំរើន និងបញ្ហាដែលកើតមានឡើងនៅក្នុងគំរោងកម្មវិធី នៅពេលដែលវាដំណើរការ ។
- ជាទូទៅ ដើរតួនាទីជាអ្នកអនុវត្តជាជាងអ្នកគ្រប់គ្រង ដូច្នេះគាត់ហាក់ដូចជាដណ្តើមការងាររបស់អ្នកនៅខាងក្រោមគាត់ធ្វើ ។

## ២. <u>តួនាទី និងមុខងាររបស់អ្នកគ្រប់គ្រង</u> : (Role and Function)

ដោយផ្អែកទៅលើរបៀបគ្រប់គ្រងបែបទំនើប អ្នកគ្រប់គ្រងគំរោងកម្មវិធីតាមបែបជឿនលឿនមួយ ត្រូវបានជឿជាក់ថា និងអនុវត្តតួនាទីដូចខាងក្រោម :

- ជាអ្នកស្រាវជ្រាវ

- ជាអ្នកធ្វើផែនការ
- ជាអ្នករៀបចំ
- ជាអ្នកដឹកនាំ/សំរបសំរួល
- ជាអ្នកត្រួតពិនិត្យ
- ជាអ្នកអោយតំលៃ

គួរកត់សំគាល់ថា អ្នកអនុវត្តមិនមែនជាតួនាទីរបស់អ្នកគ្រប់គ្រងឡើយ ។ នេះជាតួនាទីរបស់គាត់នៅពេលដែលគាត់ជាបុគ្គលិកធ្វើការនៅក្នុងសហគមន៍ ។ ដូច្នេះតួនាទីជាអ្នកអនុវត្ត គួរទុកអោយបុគ្គលិករបស់គាត់ធ្វើ ។ ដើម្បីអោយបុគ្គលិកសហគមន៍របស់គាត់អនុវត្តការងារបានល្អ អ្នកគ្រប់គ្រងត្រូវតែបន្តការលើកទឹកចិត្តដល់ពួកគេ ដោយគិតពីការងារសំរាប់អនាគតរបស់គេ ។

ដើម្បីអនុវត្តតួនាទីផ្សេងៗដំបូង អ្នកគ្រប់គ្រងគួរមើលបុគ្គលិកណាដែលអាចធ្វើការណាបានទៅតាមជំនាញ និងភាពខ្លាំងរបស់គេ ។ ទោះជាយ៉ាងណាក៏ដោយ តួនាទីដែលគាត់ត្រូវធ្វើផ្ទាល់នោះ មានដូចខាងក្រោម :

- ជាអ្នកធ្វើផែនការ
- ជាអ្នករៀបចំ
- ជាអ្នកដឹកនាំ/សំរបសំរួល

ហើយការងារដែលអាចផ្ទេរអោយអ្នកដទៃធ្វើនោះមាន :

- ជាអ្នកស្រាវជ្រាវ
- ជាអ្នកត្រួតពិនិត្យ
- ជាអ្នកវាយតំលៃ

## ៣. រូបមន្តដែលមានជ័យជំនះ : (Success formula)

រូបមន្តដែលមានជ័យជំនះ សំរាប់អ្នកគំរោងកម្មវិធីអភិវឌ្ឍន៍ ។ រូបមន្តនេះ ត្រូវបានបង្ហាញដូចខាងក្រោម :

- *ការយល់ដឹងពីគំរោងកម្មវិធី* មានន័យថា មានការយល់ដឹងពីធាតុផ្សេងៗនៃគំរោងកម្មវិធីដូចជា គោលបំណង, សកម្មភាព, លទ្ធផល, ឥទ្ធិពល និងឥទ្ធិពលយូរអង្វែង និងការទំនាក់ទំនងទៅវិញទៅមករបស់វា និងដំណើរការ ។

- *ការយល់ដឹងពីការគ្រប់គ្រង* មានន័យថា ការយល់ដឹងពីជំហាននៅក្នុងវដ្តគ្រប់គ្រង ដូចជាការស្រាវជ្រាវការធ្វើផែនការ, ការគ្រប់គ្រងបុគ្គលិក/រៀបចំ, ការដឹកនាំ/ការសំរបសំរួល ការត្រួតពិនិត្យ និងការវាយតំលៃ ។
- *បំពេញតួនាទីជាអ្នកគ្រប់គ្រង* មានសារៈសំខាន់ណាស់ ចំពោះអ្នកគ្រប់គ្រងដែលពីមុនជាបុគ្គលិកសហគមន៍ ហើយត្រូវគេដំឡើងទៅជាអ្នកគ្រប់គ្រង ឬអ្នកស្រាវជ្រាវដ៏ល្អ ទៅជាអ្នកគ្រប់គ្រង ។ គេត្រូវតែទទួលស្គាល់ថា គេជាអ្នកគ្រប់គ្រង គឺមិនមែនជាបុគ្គលិកសហគមន៍ ឬជាអ្នកស្រាវជ្រាវទៀតឡើយ ។

ការគ្រប់គ្រងគំរោងកម្មវិធីដោយធ្វើអោយងាយស្រួល ដោយចាប់ផ្តើមគំរោងកម្មវិធីទៅតាមចំណុចសំខាន់ៗដូចខាងក្រោម :

- ជ័យជំនះនៃគំរោងកម្មវិធីមួយ អាស្រ័យទៅនឹងគោលបំណងដែលយើងបានទទួល ដែលមានចែងក្នុងឯកសារនៃគំរោងកម្មវិធី ។ ដូច្នេះគោលបំណងត្រូវតែច្បាស់លាស់ ហើយអាចវាស់វែងបាន ។
- ពិភាក្សាយ៉ាងលំអិតទៅលើចំណុចសំខាន់ៗនៃឯកសារគំរោងកម្មវិធី ជាពិសេសគោលបំណង លទ្ធផល, សកម្មភាព និងធនធានបញ្ចូលជាមួយនឹងបុគ្គលិកគំរោងកម្មវិធីទាំងអស់ និងតួនាទីរបស់របស់គេនៅក្នុងការធ្វើអោយបំណងក្លាយជាការពិត ។
- យកចិត្តទុកដាក់ទៅលើលទ្ធផល - និងសកម្មភាពដែលបានបង្ហាញនៅក្នុងឯកសារគំរោងកម្មវិធីនៅអំឡុងពេលដំណើរការអនុវត្តន៍ ។
- បង្កើត និងបញ្ចូលប្រព័ន្ធត្រួតពិនិត្យសាមញ្ញមួយដែលផ្តោតទៅលើលទ្ធផល ដើម្បីកំណត់ភាពអាចទទួលជោគជ័យបាននៅក្នុងការអនុវត្តគំរោងកម្មវិធី ។
- បង្កើតការវាយតំលៃនៅក្នុងអំឡុងពេលនៃគំរោងកម្មវិធី ដើម្បីកំណត់ឥទ្ធិពល និងឥទ្ធិពលយូរអង្វែងនៃលទ្ធផល និងសកម្មភាពនៃគំរោងកម្មវិធីផ្សេងៗទៅលើអ្នកចូលរួម ។
- ប្រើប្រាសស់លទ្ធផលនៃការពិនិត្យ ដើម្បីបង្កើនភាពដែលអាចទទួលបានជោគជ័យជំនះនៃដំណើរការអនុវត្តន៍គំរោងកម្មវិធី ។
- ប្រើប្រាស់លទ្ធផលនៃការវាយតំលៃ ដើម្បីបង្កើនប្រសិទ្ធិភាពនៃសកម្មភាពផ្សេងៗ ។
- អនុវត្តន៍ប្រកបដោយមនសិការនូវតួនាទីជាអ្នកគ្រប់គ្រង និងទុកការងារអនុវត្តន៍អោយដល់ភ្នាក់ងាររបស់អ្នក ។

☞ **ចំណុចនាំងអស់ខាងលើអាចធ្វើអោយគំរោងអភិវឌ្ឍន៍របស់អ្នកទទួលបានជោគជ័យ ៖**

# កិច្ចសន្យាឥណទាននិងសន្សំប្រាក់

កម្មវិធីអភិវឌ្ឍន៍ចំរុះឃុំ........................

ភូមិ..........................

កម្មវិធីឥណទាន និងសន្សំប្រាក់ វគ្គទី...... រយៈពេល.........ខែ

ពីថ្ងៃទី...... ខែ......... ដល់ថ្ងៃទី...... ខែ......... ឆ្នាំ ២០០២

ក្រុម......... ប៉ែកទី..........

## ពាក្យសុំខ្ចីទុន តាមក្រុម

| ល.រ | ឈ្មោះអ្នកខ្ចី | ភេទ | អាយុ | ចំនួនប្រាក់ដែលខ្ចី | គោលបំណង | ស្នាមមេដៃ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| | **សរុប** | | | | | |

យើងខ្ញុំដូចមានរាយនាមខាងលើនេះ ជាសមាជិកក្រុមឥណទាន និងសន្សំប្រាក់ក្រុមទី ................ ប៉ែកទី................ ភូមិ............................... បានព្រមព្រៀងខ្ចីប្រាក់ឥណទានរបស់កម្មវិធីអភិវឌ្ឍន៍ចំនួន ........................................... រៀល (ជាអក្សរ ........................................................) ដោយមានគោលបំណងប្រើប្រាស់ដូចមានចែងក្នុងតារាងខាងលើនេះ យើងខ្ញុំសូមសន្យា ដូចតទៅ :

១- យើងខ្ញុំនិងបង្វិលសងមកកម្មវិធីអភិវឌ្ឍន៍វិញជាប្រចាំយ៉ាងទៀងទាត់នូវប្រាក់ការសរុបប្រចាំវគ្គចំនួន ..................... រៀល (ជាអក្សរ ........................................................) ចំណែកឯប្រាក់ដើម ដែលត្រូវសងផ្តាច់នៅចុងបញ្ចប់វគ្គចំនួន.......... ............. រៀល (ជាអក្សរ ............................................) ត្រឹមថ្ងៃទី......... ខែ........... ឆ្នាំ ២០០២ ។

២- ប្រសិនបើសមាជិកណាមួយក្នុងក្រុមរបស់យើងខ្ញុំមិនព្រមសង យើងខ្ញុំជាសមាជិកផ្សេងៗទៀតក្នុងក្រុម និងសុខចិត្តសងជំនួសវិញ ។

៣- យើងខ្ញុំសូមសន្យាថា និងគោរពតាមគោលការណ៍ទាំងឡាយរបស់កម្មវិធីអភិវឌ្ឍន៍ ។

៤- ដើម្បីជាសំអាង យើងខ្ញុំជាសមាជិកក្នុងក្រុមដូចរាយនាមខាងលើ សូមផ្តិតមេដៃ ដូចខាងក្រោម :

| ប្រធានក្រុមទី ..... | សមាជិកទី១ | សមាជិកទី២ | សមាជិកទី៣ | សមាជិកទី៤ | សមាជិកទី៥ |
|---|---|---|---|---|---|
| ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ |
| ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ |

បានឃើញ និង ឯកភាព

| | |
|---|---|
| ប្រធានប្រតិបត្តិភូមិ................. | ប្រធានប៉ែកទី .................. |
| ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ |
| ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ |

ស៊ីដះស_កម្ពុជា

# កម្មវិធីអភិវឌ្ឍន៍ចំរុះឃុំ........................

## កម្មវិធីឥណទាននិងសន្សំប្រាក់ វគ្គទី...... រយៈពេល.........ខែ

## ពីថ្ងៃទី...... ខែ......... ដល់ថ្ងៃទី...... ខែ......... ឆ្នាំ ២០០២

## ក្រុម......... ប៉ែកទី..........

## ពាក្យសុំខ្ចីទុន តាមប៉ែក

| ប៉ែក | ចំនួនក្រុម | ចំនួនសមាជិក | | ចំនួនប្រាក់សុំខ្ចី | ចំនួនប្រាក់ត្រូវសង | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | | ដើម | ការ | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| **សរុប** | | | | | | | |

យើងខ្ញុំជាប្រធានប៉ែកនិងជាប្រធានក្រុមក្នុងភូមិ.......................................................... បានព្រមព្រៀងគ្នាខ្ចីប្រាក់ឥណទានរបស់កម្មវិធីអភិវឌ្ឍន៍ ចំនួន ................................ រៀល (ជាអក្សរ .......................................................................) ដូចភ្ជាប់ជាមួយពាក្យសុំខ្ចីទុនតាមក្រុម ។

តាងនាមយើងខ្ញុំដូចមានរាយឈ្មោះខាងក្រោម យើងខ្ញុំមានកិត្តិយស និងសន្យាថា :

១- សមាជិកឥណទានទាំងអស់ និងគោរពនូវរាល់គោលការណ៍ទាំងឡាយរបស់កម្មវិធីអភិវឌ្ឍន៍ ។

២- យើងខ្ញុំនិងសងមកកម្មវិធីអភិវឌ្ឍន៍វិញនូវប្រាក់ដើមដែលបានខ្ចីចំនួន...................... រៀល (ជាអក្សរ.........................................................) និងប្រាក់ការសរុបចំនួន...................... រៀល (ជាអក្សរ...................................................) នៅចុងវគ្គ ត្រឹមថ្ងៃទី...... ខែ......... ឆ្នាំ ២០០២ ។

៣- ដើម្បីជាសំអាង យើងខ្ញុំជាប្រធានប៉ែក និងជាប្រធានក្រុម សូមផ្តិតមេដៃ និងឈ្មោះធានាដូចខាងក្រោម :

| | | | | | |
|---|---|---|---|---|---|
| ប្រធានក្រុមទី ..... | ប្រធានក្រុមទី ..... | ប្រធានក្រុមទី ..... | ប្រធានក្រុមទី ..... | ប្រធានក្រុមទី ..... | ប្រធានក្រុមទី ..... |
| ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ |
| ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ |

បានឃើញ និង ឯកភាព

| | |
|---|---|
| ប្រធានប្រតិបត្តិភូមិ................. | ប្រធានប៉ែកទី .................. |
| ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ |
| ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ |

ស៊ីដសេ_កម្ពុជា

## កម្មវិធីអភិវឌ្ឍន៍ចំរុះឃុំ.........................

## កម្មវិធីឥណទាននិងសន្សំប្រាក់ វគ្គទី...... រយៈពេល.........ខែ

## ពីថ្ងៃទី...... ខែ......... ដល់ថ្ងៃទី...... ខែ......... ឆ្នាំ ២០០២

# <u>ពាក្យសុំខ្ចីទុន តាមភូមិ</u>

| ប៉ែក | ចំនួនក្រុម | ចំនួនសមាជិក | | ចំនួនប្រាក់សុំខ្ចី | ចំនួនប្រាក់ត្រូវសង | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | | ដើម | ការ | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| **សរុប** | | | | | | | |

យើងខ្ញុំជាប្រធានប្រតិបត្តិភូមិ និងជាប្រធានប៉ែកក្នុងភូមិ.................................................... បានព្រមព្រៀងគ្នាខ្ចីប្រាក់ឥណទានរបស់កម្មវិធីអភិវឌ្ឍន៍ ចំនួន .................................. រៀល (ជាអក្សរ .........................................................................) ដូចភ្ជាប់ជាមួយពាក្យសុំខ្ចីទុនតាមក្រុម ។

តាងនាមយើងខ្ញុំដូចមានរាយឈ្មោះខាងក្រោម យើងខ្ញុំមានកិត្តិយស និងសន្យាថា :

១- សមាជិកឥណទានទាំងអស់ និងគោរពនូវរាល់គោលការណ៍ទាំងឡាយរបស់កម្មវិធីអភិវឌ្ឍន៍ ។

២- យើងខ្ញុំនិងសងមកកម្មវិធីអភិវឌ្ឍន៍វិញនូវប្រាក់ដើមដែលបានខ្ចីចំនួន....................... រៀល (ជាអក្សរ........................................................................)

និងប្រាក់ការសរុបចំនួន........................ រៀល (ជាអក្សរ..................................................) នៅចុងវគ្គ ត្រឹមថ្ងៃទី....... ខែ......... ឆ្នាំ ២០០២ ។

៣- ដើម្បីជាសំអាង យើងខ្ញុំជាប្រធានប្រតិបត្តិភូមិ និងជាប្រធានប៉ែក សូមផ្តិតមេដៃ និងឈ្មោះធានាដូចខាងក្រោម :

| | | | | | |
|---|---|---|---|---|---|
| ប្រធានប្រតិបត្តិភូមិ .... | ប្រធានប៉ែកទី ..... | ប្រធានប៉ែកទី ..... | ប្រធានប៉ែកទី ..... | ប្រធានប៉ែកទី ..... | ប្រធានប៉ែកទី ..... |
| ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ |
| ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ |

## បានឃើញ និង ឯកភាព

| | |
|---|---|
| អ្នកគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍សហគមន៍ឃុំ......... | ប្រធានគណកម្មការអភិវឌ្ឍន៍ឃុំ......... |
| ថ្ងៃ....ខែ.....ឆ្នាំ២០០២ | ថ្ងៃ....ខែ.....ឆ្នាំ២០០២ |
| ស្នាមមេដៃនិងឈ្មោះ | ស្នាមមេដៃនិងឈ្មោះ |

កម្មវិធីអភិវឌ្ឍន៍ចំរុះឃុំ.........................

# តារាងត្រួតពិនិត្យតាមដានការសងប្រាក់ការ តាមប៉ែក

ភូមិ.............. ប៉ែកទី...........

កម្មវិធីឥណទាននិងសន្សំប្រាក់ វគ្គទី...... រយៈពេល..........ខែ

ពីថ្ងៃទី....... ខែ.......... ដល់ថ្ងៃទី....... ខែ.......... ឆ្នាំ ២០០២

## ការសងការប្រាក់ប្រចាំខែ...........

| ល.រ | ឈ្មោះប្រធានក្រុម | ចំនួនប្រាក់ដើមបានខ្ចីក្នុងក្រុម | ចំនួនការប្រាក់ដែលបានសងប្រចាំខែ | ថ្ងៃ/ខែ/ឆ្នាំ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |
| ១០ | | | | | |
| ១១ | | | | | |
| ១២ | | | | | |
| | សរុប | | | | |

បានឃើញ និង ឯកភាព
ប្រធានប្រតិបត្តិភូមិ..............
ថ្ងៃ....ខែ.....ឆ្នាំ២០០២
ស្នាមមេដៃនិងឈ្មោះ

អ្នកទទួល
ប្រធានប៉ែកទី ..............
ថ្ងៃ....ខែ.....ឆ្នាំ២០០២
ស្នាមមេដៃនិងឈ្មោះ

# តារាងបូកសរុបប្រចាំវគ្គ

## វគ្គទី...........

**ពីថ្ងៃទី...... ខែ......... ដល់ថ្ងៃទី...... ខែ......... ឆ្នាំ ២០០២**

**កម្មវិធីអភិវឌ្ឍន៍ចំរុះឃុំ .................. ភូមិ ................. ប៉ែកទី ............**

| ល.រ | ឈ្មោះប្រធានក្រុម | ចំនួនសមាជិក | ចំនួនទឹកប្រាក់ត្រូវសង (រៀល) | ចំនួនទឹកប្រាក់ត្រូវសង | | ចំនួនទឹកប្រាក់បានសងជាក់ស្តែង (រៀល) | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ដើម | ការ | ដើម | % | ការ | % | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

អ្នកគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍សហគមន៍ឃុំ..........
ថ្ងៃ.......ខែ...........ឆ្នាំ២០០២
ស្នាមមេដៃ និង ឈ្មោះ

ប្រធានគណកម្មការអភិវឌ្ឍន៍ឃុំ...........
ថ្ងៃ.......ខែ...........ឆ្នាំ២០០២
ស្នាមមេដៃ និង ឈ្មោះ

ប្រធានប្រតិបត្តិភូមិ............
ថ្ងៃ.......ខែ...........ឆ្នាំ២០០២
ស្នាមមេដៃ និង ឈ្មោះ

ប្រធានប៉ែកទី...........
ថ្ងៃ.......ខែ...........ឆ្នាំ២០០២
ស្នាមមេដៃ និង ឈ្មោះ

# <u>បញ្ជីសាច់ប្រាក់</u>

| លេខឯកសារ | ថ្ងៃ/ខែ/ឆ្នាំ | បរិយាយ | រៀល | | ដើម | ការ | % ដើម | % ការ | សមតុល្យ |
|---|---|---|---|---|---|---|---|---|---|
| | | | ចូល | ចេញ | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

# កិច្ចសន្យាកូនគោ

## (Offspring agreement)

១- អ្នកដែលជាសមាជិកធនាគារគោ គឺជាអ្នកទាំងឡាយណាដែលអ្នកភូមិ ចាត់ទុកថាជាអ្នកក្រ ។

២- មិនបានផ្តល់អោយអ្នកណាមួយ ដែលទើបនិងលក់កំលាំងអូសទាញមួយឆ្នាំមុន ។

៣- អ្នកទទួលកូនគោមេទៅចិញ្ចឹម ត្រូវមានរបងព័ទ្ធជុំវិញផ្ទះ ធ្វើក្រោលសំរាប់ដាក់គោ និងធ្វើរោងជី ដើម្បីសន្សំជីធម្មជាតិអោយបានត្រឹមត្រូវ ។

៤- អ្នកដែលបានទទួលកូនគោមេ ឬឈ្មោល ទៅចិញ្ចឹមដំបូងត្រូវបង់ស្រូវវិភាគចំនួន ២ តៅ តំកល់ទុកក្នុងសហគមន៍ធនាគារស្រូវភូមិ ធ្វើដូចនេះសំរាប់បង្ការទៅថ្ងៃអនាគតនៅពេលគោឈឺងាប់ ដើម្បីអោយសហគមន៍មានទុនបង្វិលសត្វមកវិញ ។

៥- ចំពោះកូនគោមេដែលត្រូវបំបែកអោយទៅសមាជិកថ្មីទៀតនោះ ត្រូវទុកជាមេគោពូជ ដើម្បីយកកូនចែកអោយសមាជិកចិញ្ចឹមយកកូនបន្តទៀត ។

៦- ចំពោះកូនគោកើតលើកទី ១ ជាឈ្មោលត្រូវបំបែកអោយអ្នកចិញ្ចឹមមេ ។ បើកូនលើកទី ២ ឈ្មោលទៀត គណកម្មការត្រូវដកយកមកដូររកកូនមេបំបែកអោយអ្នកផ្សេងទៀត ។ បើកូនលើកទី ១ ជាមេត្រូវយកមកអោយអ្នកផ្សេងចិញ្ចឹម ក្នុងករណីកូនលើកទី ២ ជាមេទៀត ត្រូវយកកូនមេនោះទៅរកដូរយកកូនឈ្មោលមកអោយអ្នកចិញ្ចឹមកូនមេដំបូង ( ត្រូវដូរគោក្នុងសហគមន៍) ។ ចំពោះកូនគោមេត្រូវបំបែកនោះ ទោះបីអោយអ្នកណាទទួលក៏ដោយ ត្រូវចាត់ទុកជាមេគោពូជដែរ ។

៧- អ្នកទទួលកូនគោមេទៅចិញ្ចឹម មិនអនុញ្ញាតិអោយលក់ដូរ ឬជួលអោយអ្នកដទៃទៀតដោយគ្មានការអនុញ្ញាតិ និងត្រួតពិនិត្យច្បាស់លាស់ពីគណកម្មការអភិវឌ្ឍន៍ឃុំបានឡើយ ។

៨- ចំពោះសមាជិកណាម្នាក់ផ្លាស់ប្តូរទីលំនៅសព្វថ្ងៃចេញទៅនៅក្រៅភូមិ មិនអនុញ្ញាតិអោយយកគោទៅតាមខ្លួនបានឡើយ ។ ព្រោះវាជាសម្បត្តិរបស់ភូមិ ហើយគណកម្មការត្រូវដកហូតអោយអ្នកផ្សេងទៀត ។ លើកលែងតែចំណែករបស់ខ្លួនដែលត្រូវបាន ចំពោះស្រូវវិភាគទានគោ មិនបានប្រគល់វិញឡើយ ក្រោយពីប្រើប្រាស់បានមួយឆ្នាំកន្លងមក ។

៩- ប្រសិនបើកូនគោមេនោះចិញ្ចឹមបាន ៥ ឆ្នាំហើយ មិនអាចផ្តល់កូនអោយបានអ្នកចិញ្ចឹមត្រូវពិគ្រោះជាមួយគណកម្មការ ដើម្បីផ្លាស់ប្តូររកមេគោថ្មីទៀតមកចិញ្ចឹម ។

១០- អ្នកចិញ្ចឹមត្រូវយកស្មារតីខ្ពស់ទទួលខុសត្រូវក្នុងការថែទាំការងារ ចាក់ថ្នាំព្យាបាលដោយខ្លួនឯងក្នុងករណីដែលមានជំងឺធ្ងន់ធ្ងរ ត្រូវរាយការណ៍ជាបន្ទាន់អោយគណកម្មការ ។ បើគោងាប់ ឬបាត់បង់ដោយខ្វះការប្រុងប្រយ័ត្ន ត្រូវចាប់បង់អោយសងមេគោវិញជាបន្ទាន់ និងត្រូវដកអោយអ្នកផ្សេងទៀតចិញ្ចឹម ។

១១- អ្នកទទួលមេគោទៅចិញ្ចឹម និងគណកម្មការអភិវឌ្ឍន៍ភូមិ ត្រូវអនុវត្តតាមកិច្ចសន្យានេះអោយបានទៀងទាត់ និងមានប្រសិទ្ធិភាព ។

យោងតាមប្រការខាងលើក្នុងកិច្ចសន្យានេះ ខ្ញុំបាទ. នាងខ្ញុំដែលជាសមាជិកធនាគារគោ ក្នុងភូមិសូមសន្យា និងគោរពអោយបាន ។ ប្រសិនបើខ្ញុំបាទ.នាងខ្ញុំ គោរពមិនបាននូវប្រការណាមួយ គណកម្មការមានសិទ្ធិដកហូតយកគោ និងបណ្តេញចេញពីសមាជិកធនាគារគោ ។

ធ្វើនៅថ្ងៃទី........ ខែ............ ឆ្នាំ............

| | | | |
|---|---|---|---|
| គណកម្មការអភិវឌ្ឍន៍ភូមិ..................... | | ស្នាមមេដៃអ្នកទទួលគោចិញ្ចឹម | |
| ស្នាមមេដៃ | ស្នាមមេដៃ | ប្តី | ប្រពន្ធ |

| | | | |
|---|---|---|---|
| ឈ្មោះ............................ | ឈ្មោះ............................ | ឈ្មោះ............................ | ឈ្មោះ............................ |
| ស្នាមមេដៃ | ស្នាមមេដៃ | ស្នាមមេដៃ | ស្នាមមេដៃ |

កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ

ស៊ីដសេ ស្រុកជុំគិរី ខេត្តកំពត

គំរោងកម្មវិធីធនាគារគោ

# តារាងត្រួតពិនិត្យសកម្មភាពធនាគារគោ

ក្រុមទី : ...........                                        សំរាប់ខែ : ................ ឆ្នាំ ២០០.....

| ល.រ | ឈ្មោះ សមាជិក | ភេទ | | សមាជិក | | ចំនួនគោ ទទួល | ថ្ងៃ/ខែ/ឆ្នាំ ទទួល | គោបង្វិល មក ស.ភ | ថ្ងៃ/ខែ/ឆ្នាំ បង្វិល | គោទទួល | | កូនគោកើតថ្មី | | កូនរឺមេគោងាប់ | | ចំនួនគោ រស់សរុប | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្រី | ប្រុស | មុន | ក្រោយ | | | | | ស៊ីដសេ | ស.ភ | ញី | ឈ្មោល | ញី | ឈ្មោល | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
ប្រធានក្រុម

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
អនុគណកម្មការធនាគារគោ

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
គណកម្មការអភិវឌ្ឍន៍ភូមិ

កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ

ស៊ីដះសេកំពត

ភូមិ .................... ឃុំ ....................

ស្រុក .................... ខេត្ត ....................

# គំរោងកម្មវិធីធនាគារគោ

| ល.រ | ថ្ងៃ/ខែ/ឆ្នាំ ផ្តល់ | ឈ្មោះអ្នកទទួលផល | ភេទ | ក្រុម | ចំនួនមេគោដែលបានផ្តល់ | | | កូនគោដែលបានទទួលជាកម្មសិទ្ធិ | | មេគោបង្វិលអោយសហគមន៍វិញ | | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ស៊ីដសេ | ស.គ | សរុប | ញី | ឈ្មោល | ចំនួន | ថ្ងៃ/ខែ/ឆ្នាំ បង្វិល | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ

ស៊ីដសេ ស្រុកជុំគីរី ខេត្តកំពត

គំរោងកម្មវិធីធនាគារគោ

# តារាងត្រួតពិនិត្យសកម្មភាពធនាគារគោ

សំរាប់ខែ : ................ ឆ្នាំ ២០០.....

| ល.រ | ក្រុមទី | ថ្ងៃ/ខែ/ឆ្នាំ ផ្តល់និងសង | ចំនួនសមាជិក | | សមាជិកថ្មី | | សមាជិកសរុប | ចំនួនគោផ្តល់ដោយស៊ីដសេ | គោពង្រីកដោយស.គ | កូនគោរស់សរុប | | កូនគោកើតថ្មី | | ចំនួនកូនគោ រឺ មេគោងាប់ | | ចំនួនគោរស់សរុប | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ស្រី | ប្រុស | ស្រី | ប្រុស | | | | ញី | ឈ្មោល | ញី | ឈ្មោល | ស៊ីដសេ | សហគមន៍ | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | |

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
បុគ្គលិកស៊ីដសេ

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
អនុគណកម្មការធនាគារគោ

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
គណកម្មការអភិវឌ្ឍន៍ភូមិ

កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ
ស៊ីដសេ ស្រុកជុំគីរី ខេត្តកំពត
គំរោងកម្មវិធីធនាគារស្រូវ

# តារាងត្រួតពិនិត្យសកម្មភាពធនាគារស្រូវ

ក្រុមទី :............ វគ្គទី : ............ សំរាប់ខែ : ................ ឆ្នាំ ២០០.....

| ល.រ | ឈ្មោះ សមាជិក | ភេទ | | សមាជិក | | ចំនួនស្រូវ ខ្ចី គ.ក្រ | កាលបរិច្ឆេទ ខ្ចីស្រូវ | កាលបរិច្ឆេទ សងស្រូវ | ចំនួនស្រូវសងជាក់ស្តែង | | ចំនួនស្រូវ សងសរុប | ស្រូវនៅជំពាក់ | | % ស្រូវ សងសរុប | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | មុន | ក្រោយ | | | | ដើម | ការ | | ដើម | ការ | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
ប្រធានក្រុម

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
អនុគណកម្មការធនាគារស្រូវ

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......
គណកម្មការអភិវឌ្ឍន៍ភូមិ

កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ

ស៊ីដសេ កំពត

ភូមិ ...................... ឃុំ ......................

ស្រុក..................... ខេត្ត ......................

# គំរោងកម្មវិធីធនាគារស្រូវ

| ល.រ | ឈ្មោះសមាជិក | ភេទ | ថ្ងៃ/ខែ/ឆ្នាំ | វគ្គទី | ចំនួនស្រូវខ្ចី គ.ក្រ | ថ្ងៃ/ខែ/ឆ្នាំ សង | ចំនួនស្រូវត្រូវសង គ.ក្រ | | ចំនួនស្រូវសងជាក់ស្តែង គ.ក្រ | | ចំនួនស្រូវនៅខ្វះ គ.ក្រ | | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដើម | ការ | ដើម | ការ | ដើម | ការ | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ

ស៊ីដសេ កំពត

ភូមិ ..................... ឃុំ .....................

ស្រុក..................... ខេត្ត .....................

# របាយការណ៍សរុបនៃគំរោងកម្មវិធីធនាគារស្រូវ

| វគ្គទី | ឆ្នាំ | ចំនួនសមាជិក | ភេទ | | ស្រូវផ្តល់ដោយ ស៊ីដសេ. ស.គ | ស្រូវអោយខ្ចីសរុប គ.ក្រ | ស្រូវដើមសង គ.ក្រ | ស្រូវការសង គ.ក្រ | ％ដើមសង | ％ការសង | ដើមនិងការសរុប គ.ក្រ | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប្រុស | ស្រី | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| សរុប | | | | | | | | | | | | |

ថ្ងៃទី......... ខែ............. ឆ្នាំ ២០០.....

កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះ

ស៊ីដសេ ស្រុកជុំគិរី ខេត្តកំពត

គំរោងកម្មវិធីធនាគារស្រូវ

# តារាងត្រួតពិនិត្យសកម្មភាពធនាគារស្រូវ

សំរាប់ខែ : ................ ឆ្នាំ ២០០.....

| ល.រ | ក្រុមទី | ថ្ងៃ/ខែ/ឆ្នាំ ផ្តល់និងសង | សមាជិកសរុប | | សមាជិកថ្មី | | សមាជិក សរុប | ចំនួនស្រូវផ្តល់ ដោយស៊ីដសេ | ស.ត ផ្តល់ ស្រូវអោយ ខ្ចីសរុប | ចំនួនស្រូវត្រូវ សងសរុប | | ចំនួនស្រូវសងជាក់ស្តែង | | | % ស្រូវសងជាក់ស្តែង | | % ស្រូវសង សរុប | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ប្រុស | ស្រី | ប្រុស | ស្រី | | | | ដើម | ការ | ដើម | ការ | សរុប | ដើម | ការ | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......

បុគ្គលិកស៊ីដសេ

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......

អនុគណកម្មការធនាគារស្រូវ

ថ្ងៃ......... ខែ........... ឆ្នាំ ២០០.......

គណកម្មការអភិវឌ្ឍន៍ភូមិ

ស៊ីដសេកំពត

ស្រុកជុំគីរី

កម្មវិធីធនាគារស្រូវភូមិ

# ពាក្យសុំខ្ចីស្រូវរបស់សមាជិក

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................ ភេទ........ អាយុ.......... ឆ្នាំ មានទីលំនៅភូមិ........................ ឃុំ.................. ស្រុកជុំគីរី ខេត្តកំពត ។ ជាសមាជិកក្នុងក្រុមធានាគ្នាទី.......... មានសេចក្តីរីករាយសុំខ្ចីស្រូវចំនួន.............. គ.ក្រ ពីធនាគារស្រូវភូមិ...................... ឃុំ...................... ស្រុកជុំគីរី ខេត្តកំពត ឆ្លងតាមរយៈក្រុមធានាគ្នាទី.......... ដើម្បីយកទៅផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារនៅរដូវខ្វះខាតខាងមុខនេះ ហើយនិងបង្វិលសងមកវិញនូវស្រូវចំនួន .................. គ.ក្រ ក្នុងវគ្គទិ............. ចាប់ពីគិតពីថ្ងៃទី.......... ខែ.............. ឆ្នាំ ២០០.... ដល់ថ្ងៃទី......... ខែ............ ឆ្នាំ ២០០..... ។

ខ្ញុំបាទ-នាងខ្ញុំ សូមគោរពនូវបទបញ្ជា និងគោលការណ៍របស់ក្រុមធានាគ្នា និងគោលការណ៍របស់កម្មវិធីធនាគារស្រូវភូមិ ដោយធានាថា មិនធ្វើអោយខុស ឬមិនសងឡើយ ។

ដើម្បីជាភស្តុតាងខ្ញុំបាទ-នាងខ្ញុំសូមផ្តិតមេដៃជាចំណាំ :

ធ្វើនៅភូមិ................ ថ្ងៃទី......... ខែ............ ឆ្នាំ ២០០......

| | | |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| អនុគណកម្មការធនាគារស្រូវភូមិ | ប្រធានក្រុមធានា | អ្នកខ្ចី |
| ........................................... | ......................................... | ........................................... |

ស៊ីដសេកំពត

ស្រុកជុំគីរី

កម្មវិធីធនាគារស្រូវភូមិ

# ពាក្យសុំខ្ចីស្រូវរបស់ក្រុម

យើងខ្ញុំតំណាងអោយសមាជិកក្រុមធានាគ្នាទី......... នៃកម្មវិធីធនាគារស្រូវភូមិ.................... ឃុំ...................... ស្រុកជុំគីរី ខេត្តកំពត ។

មានសេចក្តីរីករាយសុំខ្ចីស្រូវចំនួន.......................... គ.ក្រ ពីកម្មវិធីធនាគារស្រូវភូមិ......................... ឃុំ....................... ស្រុកជុំគីរី ខេត្តកំពត ដើម្បីយកទៅផ្គត់ផ្គង់ជីវភាពគ្រួសាររបស់សមាជិកនៃក្រុមធានាគ្នាទី......... ដែលកំពុងខ្វះខាត ហើយយើងខ្ញុំ នឹងបង្វិលសងស្រូវវិញក្នុងការិតចំនួន......................... គ.ក្រ ។

ក្នុងវគ្គទី.............. ចាប់ពីថ្ងៃទី............ ខែ................. ឆ្នាំ២០០...... ដល់ថ្ងៃទី............ ខែ................. ឆ្នាំ ២០០...... ដោយភ្ជាប់មកជាមួយនូវបញ្ជីរាយនាមសមាជិក និងកិច្ចសន្យាចំនួន ១ច្បាប់ យើងខ្ញុំតំណាងអោយសមាជិកទាំងអស់ សូមគោរពនូវគោលការណ៍នៃកម្មវិធីធនាគារស្រូវភូមិ ដោយធានាថាមិនធ្វើអ្វីអោយខុស ឬមិនសងឡើយដើម្បីជាសំអាងយើងខ្ញុំសូមចុះហត្ថលេខា ឬស្នាមមេដៃជាចំណាំ :

ធ្វើនៅភូមិ................ ថ្ងៃទី......... ខែ........... ឆ្នាំ ២០០......

| | | |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| ភ្នាក់ងារអង្គការស៊ីដសេ | អនុគណកម្មការធនាគារស្រូវភូមិ | ១. ប្រធានក្រុម.......................... |
| | | ២. លេខាក្រុម.......................... |
| | | ៣. ហិរញ្ញិកក្រុម........................ |
| ........................................ | ............................................. | |

# របាយការណ៍ក្រុមជួយខ្លួនឯង ប្រចាំខែ............. ឆ្នាំ ២០០២

| ល.រ | ឈ្មោះភូមិ | ចំនួនសមាជិក | | | ថ្ងៃខែឆ្នាំកំណើត | ប្រាក់សន្សំសរុប | ការប្រាក់លើប្រាក់សន្សំ | ប្រាក់ខ្ចីពីធនាគារឃុំ | សងដើមវិលោះពីធនាគារឃុំ | ការប្រាក់ ១៖សងទៅធនាគារឃុំ | ការប្រាក់ ២៖ទុកក្នុងក្រុម | ប្រាក់សន្សំខ្ចីពីក្រុម | ប្រាក់សល់នៅក្នុងក្រុម |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | | | | | | | | | |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | |

ធ្វើ. ថ្ងៃទី............. ខែ................. ឆ្នាំ២០០.......

**គណៈកម្មការអភិវឌ្ឍន៍ឃុំ**

# ផ្នែកទី១ ~ សន្សំលុយ

ឈ្មោះសមាជិក :

លេខសំគាល់ :

| ល.រ | ថ្ងៃ/ខែ/ឆ្នាំ | ប្រាក់សន្សំ | | | | | ហត្ថលេខាប្រធានក្រុម |
|---|---|---|---|---|---|---|---|
| | | ចូល | | | ចេញ | | |
| | | ចំនួនសន្សំ | ការប្រាក់លើប្រាក់សន្សំ | ចំនួនសរុប | ដកចេញ | សមតុល្យនៃប្រាក់សន្សំ | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

# ផ្នែកទី២ ~ ខ្ចីនិងសង

**ឈ្មោះសមាជិក :** **លេខសំគាល់ :**

| ល.រ | ថ្ងៃ/ខែ/ឆ្នាំ | គោលបំណងនៃការខ្ចីទុន | ដើមទុនខ្ចី | | ប្រាក់កម្ចីដើម និង ការ | | | | | | ប្រាក់កម្ចីហួសពេលកំណត់ | | | ប្រាក់ពិន័យ | ហត្ថលេខាប្រធានក្រុម |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួន | រយៈពេល | ប្រាក់ដើម | | | ប្រាក់ការ | | | ប្រាក់ដើម | ប្រាក់ការ | សរុប | | |
| | | | | | រំពឹង | ប្រមូលបាន | សមតុល្យ | រំពឹង | ប្រមូលបាន | សមតុល្យ | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |